# សេណារីយោនៅពីក្រោយរដ្ឋប្រហារកូនកាត់នៅរុស្ស៊ី ខែមិថុនា ឆ្នាំ២០២៣

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣ រដ្ឋាភិបាលមូស្គូ (Moscow) បានប្រកាសចាត់វិធានការប្រឆាំងភេរវកម្ម ដោយបានហាមមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋចេញពីផ្ទះឡើយ ក្រោយពេល ក្រុមទាហានស៊ីឈ្នួល វ៉ាក់ណែ (Wagner) បានលើកទ័ពចេញពីទឹកដីអ៊ុយក្រែន រួចបែរចុងកាណុងតម្រង់ឆ្ពោះទៅកាន់ទីក្រុង Moscow។ [១] ការណ៍នេះ នាំឱ្យពិភពលោក ពិសេសអ្នកតាមដានព្រឹត្តិការណ៍អន្តរជាតិហាក់មានការយកចិត្តទុកដាក់យ៉ាងខ្លាំង ព្រមទាំងមានការចោទសួរយ៉ាងខ្លាំងពីសំណាក់សាធារណជន អ្នកតាមដានព្រឹត្តិការណ៍អន្តរជាតិ ក៏ដូចជាក្នុងស្រទាប់អ្នកសិក្សាស្រាវជ្រាវ ព្រោះថាក្រុមទាហានស៊ីឈ្នួលWagner គឺជាដៃគូប្រយុទ្ធដ៏សំខាន់

---

១ ALJAZEERA: Wagner boss calls off march on Moscow, agrees to exile in Belarus ,available in https://rb.gy/ilglz, aceessed on June 26 ,2023 at 11:30 am.

របស់កងទ័ពរុស្ស៊ីនៅក្នុងសមរភូមិអ៊ុយក្រែននេះ ហើយជាពិសេសនៅតំបន់ភាគខាងកើតអ៊ុយក្រែនតែម្តង។

ម្យ៉ាងវិញទៀត ក្រុមទាហានស៊ីឈ្នួលWagner ក៏បានទទួលអាវុធពីកងទ័ពរុស្ស៊ី ដើម្បីប្រយុទ្ធនៅអ៊ុយក្រែនថែមទៀតផង។ [២] ផ្ទុយទៅវិញ នៅនំណាក់កាលចុងក្រោយនេះ ស្ថានការណ៍បានឈានទៅដល់បរិបទថ្មី ព្រោះគេពិតជាមិននឹកស្មានដល់ថា ក្រុមទាហានស៊ីឈ្នួលរុស្ស៊ី Wagner អាចងាកមកចាក់ពីក្រោយខ្នងរុស្ស៊ីវិញនោះឡើយ។

ដូច្នេះ តើក្រុម Wagner និងរុស្ស៊ីមានទំនាក់ទំនងគ្នាស្អិតរមួត និងល្អកល្អឿននឹងគ្នាដល់កម្រិតណា? ហើយតើមានដើមចមអ្វីខ្លះទើបធ្វើឱ្យ Wagner និងរុស្ស៊ីឈានដល់នំណាក់កាលបែកផ្លូវគ្នាយ៉ាងនេះ? ឬមួយសភាពការណ៍នេះគ្រាន់តែជាសេណារីយោមួយដែលគេរៀបចំឡើង ដើម្បី

---

[២] Sky news: How does Wagner Group's strength measure up to the Russian state military? ,available https://shorturl.at/pyR14, aceessed on June 26 ,2023 at 15:30 pm.

# បំភាន់ភ្នែកពិភពលោក? ឬមួយតើវាជាការបង្កើតព្រឹត្តិការណ៍ដើម្បីលុបលើព្រឹត្តិការណ៍ឬ?




រូបភាពពី
https://rb.gy/or47k

មុននឹងឈានដល់ចម្លើយនៃសំណួរទាំងអស់នេះ យើងត្រូវសម្លឹងមើលពីជ្រុងផ្សេងៗជាមុនសិន ឬយើងអាចនិយាយតាមបែបផ្សេងថា សម្លឹងមើលឱ្យបានច្រើនជ្រុងជាមុនសិន រួចចាំទាញសេចក្ដីសន្និដ្ឋានតាមក្រោយ ដោយយើងពិនិត្យមើលជ្រុងចំនួន៥ ដូចខាងក្រោម៖

## ផ្នែកទី១. អំពីក្រុមទាហានស៊ីឈ្នួល Wagner

បង្កើតឡើងដំបូងក្នុងឆ្នាំ២០១៤ ក្រុមWagner (ហៅជាផ្លូវការថា PMC Wagner) នៅពេលនោះក្រុម Wagner គាំទ្រកងកម្លាំងបំបែកខ្លួន (ក្រុមផ្តាច់ទឹកដីចេញពីអ៊ុយក្រែន) ដែលគាំទ្ររុស្ស៊ីនៅភាគខាងកើតអ៊ុយក្រែន។ នៅដំណាក់កាលនោះ Wagner មានអ្នកប្រយុទ្ធត្រឹមតែ ៥000នាក់[៣] ប៉ុណ្ណោះ ដែលភាគច្រើនជាអតីតយុទ្ធជននៃកងវរសេនាធំវរជន និងកងកម្លាំងពិសេសរបស់រុស្ស៊ី។ នៅដំណាក់កាលបន្តបន្ទាប់ក្រុម Wagner បានវិវត្តខ្លួនទៅជាអង្គការសម្ងាត់មួយដែលប្រតិបត្តិការក្នុងប្រទេសនានាមួយចំនួន រួមមានអ៊ុយក្រែន ស៊ីរី លីប៊ី សាធារណរដ្ឋអាហ្វ្រិកកណ្តាល ស៊ូដង់ ម៉ាលី និងម៉ូសំប៊ិក។

នៅក្នុងសង្គមរុស្ស៊ី ការបង្កើតក្រុមកងទ័ពស៊ីឈ្នួលគឺជារឿងខុសច្បាប់ ប៉ុន្តែនៅឆ្នាំ២០២២កន្លងទៅថ្មីៗនេះ ក្រុម Wagner បានចុះបញ្ជីជាក្រុមហ៊ុន និងបានបើកការិយា

---

៣ BBC: What is Russia's Wagner Group of mercenaries in Ukraine?,available https://rb.gy/p7mww, aceessed on June 26 ,2023 at 15:30 pm.

លើយកណ្ដាលថ្មីនៅទីក្រុង St Petersburg។[៤] នៅក្នុងឆ្នាំ ២០២៣នេះ Wagner ដឹកនាំដោយលោក ព្រីកូស៊ីន (Prigozin) ដែលមានកងទំពស៊ីឈ្នួលសរុបចំនួន ២៥០០០ ហើយទំពដែលប្រយុទ្ធនៅអ៊ុយក្រែន៨០%ជាអ្នកទោស។[៥]

មុនពេលចូលប្រយុទ្ធក្នុងសង្គ្រាម ឈ្លានពានអ៊ុយក្រែន ក្រុម Wagner បានបង់ប្រាក់ឱ្យអ្នកប្រយុទ្ធរបស់ខ្លួនក្នុងមួយខែមានត្រឹម £៤,៤០០ ឬស្មើនឹង ៥,៥៥៣.៤៩ $ប៉ុណ្ណោះ ក៏ប៉ុន្តែចំនួនទឹកប្រាក់ឈ្នួលនេះបានបង្កើនជិតពីរដង ក្រោយពេលក្រុមWagner ចូលប្រយុទ្ធនៅសមរភូមិអ៊ុយក្រែនដោយផ្ដល់ប្រាក់ចំនួន £៨,០០០ ឬស្មើនឹង

---

៤ BBC: What is Russia's Wagner Group of mercenaries in Ukraine?,available https://rb.gy/p7mww, aceessed on June 26 ,2023 at 15:30 pm.

៥ ឈាង បុប្ផា : *មេក្រុមទាហានស៊ីឈ្នួលរុស្ស៊ីWagnerបែរទិសចេញពីអ៊ុយក្រែនទៅតទល់នឹងអំណាចយោធានៅរុស្ស៊ី,* RFI,ចេញផ្សាយថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២៣,available https://rb.gy/wlml1, aceessed on June 26 ,2023 at 11:30 am.

១០,០៩៧.៥១$ ក្នុងមួយខែ។[៦] ខណៈពេលដែលប្រាក់ឈ្នួលប្រចាំខែកើនឡើងយ៉ាងនូច្ទេះ គុណភាពទាហានបានធ្លាក់ចុះ គឺថាពីមុន Wagner ជ្រើសរើសតែមនុស្សដែលមានបទពិសោធច្រើនក្នុងវិស័យយោធាប៉ុណ្ណោះ ប៉ុន្តែចាប់តាំងពីសង្គ្រាមអ៊ុយក្រែនបានចាប់ផ្តើមមក Wagner ជ្រើសរើសយកអ្នកមិនសូវមានបទពិសោធ សំខាន់ឱ្យតែហ៊ានប្រយុទ្ធ ហ៊ានពលីក្នុងសមរភូមិ។

វីឯគ្រឿងសព្វាវុធវិញ ក្រុមWagner មានអាវុធធុនធ្ងន់ អាវុធការពារដែនអាកាស និងរថយន្តប្រយុទ្ធ SA-22sជាដើម។ ក្រៅពីនោះក្រុមWagner ក៏មានយន្តហោះចម្បាំង និងមីស៊ីលរយៈចម្ងាយខ្លីផងដែរ ដែលរុស្ស៊ីជាអ្នកផ្គត់ផ្គង់ឱ្យ។ បន្ថែមពីលើនេះ ក្រុមWagner ក៏មានរថក្រោះ និងរថយន្តយោធាផ្សេងទៀត ជាច្រើនដែលពួកគេអាចប្រើប្រាស់ និងមានអានុភាពខ្លាំងក្នុងការប្រយុទ្ធ។

---

៦ Mail onlline: How many soldiers do Wagner Group have against Russia? What weapons are at their disposal?,available in https://rb.gy/1opqy, aceessed on June 27 ,2023 at 16:30 pm.




រូបភាពពី
https://rb.gy/1opqy

ចំពោះទ្រព្យសម្បត្តិរបស់ក្រុម Wagner ពិសេសរបស់លោក Yevgeny Prigozhin មេដឹកនាំក្រុម Wagner មានទ្រព្យសម្បត្តិច្រើនជាង ៨០០ លានផោន ឬប្រហែលនឹង ១ពាន់លានដុល្លារ។[៧] ប្រភពចំណូលនេះ

[៧] mail onlline: How many soldiers do Wagner Group have against Russia? What weapons are at their disposal?,available in https://rb.gy/1opqy, aceessed on June 27 ,2023 at 16:30 pm.

បានមកពីប្រតិបត្តិការធនធានធម្មជាតិ ដូចជាការទាញយកប្រេង ឧស្ម័ន ពេជ្រ និងមាស។ ដើម្បីរួចផុតពីការដាក់ទណ្ឌកម្ម ឬការបង្កកទ្រព្យសម្បត្តិពីលោកខាងលិច ក្រុម Wagner បានជ្រើសរើសការទូទាត់ដោយមិនប្រើជាលុយនោះទេ គឺទូទាត់ជាលោហធាតុ ដូចជារ៉ែ ត្បូង ពេជ្រ មាស ព្រោះវាពិបាកក្នុងការតាមដាន។ កាលពីខ្លួនធ្វើប្រតិបត្តិការនៅក្នុងប្រទេសស៊ីរី ក្រុមWagner បានទូទាត់ជាប្រេងនិងឧស្ម័ន។

ដូចនេះ តើក្រុមទាហានស៊ីឈ្នួល Wagner មានទំនាក់ជាមួយថ្នាក់ដឹកនាំរុស្ស៊ីកម្រិតណា ទើប Wagner អាចឈរជើងបាននៅក្នុងសង្គមរុស្ស៊ី ហើយបើកការិយាល័យក្រុមហ៊ុនកណ្តាលនៅរុស្ស៊ីបាន?

## ផ្នែកទី២. អំពីទំនាក់ទំនងរវាងថ្នាក់ដឹកនាំរុស្ស៊ីនិងក្រុម Wagner

មេដឹកនាំក្រុមWagner លោកPrigozhin និងលោកពូទីនប្រធានាធិបតីរុស្ស៊ី គឺជាមនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា។ អ្នកទាំងពីរមានដើមកំណើតនៅទី

ក្រុងឡេនីនក្រាតដូចគ្នា ដែលបច្ចុប្បន្ននេះមានឈ្មោះថា ទីក្រុង St. Petersburg។ កើតនៅឆ្នាំ ១៩៦១ លោក Prigozhin បានចូលរៀននៅសាលាកីឡា ដោយជ្រើសរើសប្រភេទជាអ្នកជិះស្គីឆ្លងប្រទេស។ ក្នុងវ័យជំទង់ លោកPrigozhin ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ដោយជាប់ចោទពីបទល្មើសជាច្រើន រួមទាំងចោរកម្មផង។ នៅក្នុងឆ្នាំ១៩៨១ តុលាការព្រហ្មទណ្ឌទីក្រុង Leningrad បានកាត់ទោសគាត់ឱ្យជាប់គុកសម្រាប់ឧក្រិដ្ឋកម្មផ្សេងៗ ដូចជាពីបទប្លន់ស្ត្រីម្នាក់ដោយកាំបិត និងពីបទចោរគាស់ផ្ទះនិងពីបទចោទជាច្រើនករណីផ្សេងទៀត។ [៨] លោក Prigozhin ត្រូវបានដោះលែងនៅឆ្នាំ១៩៩០ ពោលគឺមួយឆ្នាំមុនពេលការដួលរលំនៃសហភាពសូវៀត។ មិនយូរប៉ុន្មាន នាពេលក្រោយមកគាត់បានបើកកន្លែងលក់hotdogនិងបន្តបើកភោជនីយដ្ឋានជាបន្តបន្ទាប់។

---

៨ Time : What to Know About Notorious Mercenary Organization 'The Wagner Group' and Its Founder,available in https://rb.gy/ptgkf, acessed on June 27 ,2023 at 19:30 pm.

នៅដើមឆ្នាំ២០០០ នាពេលដែលលោកប្រធានាធិបតីវ័យក្មេង Vladimir Putin បានឡើងកាន់តំណែងជាប្រធានាធិបតីរុស្ស៊ី លោកបានជ្រើសរើសភោជនីយដ្ឋានរបស់លោកPrigzhinនេះ សម្រាប់ទទួលភ្ញៀវឥស្សរជនបរទេសល្បីៗ ដូចជាលោកប្រធានាធិបតីបារាំង Jacques Chirac ជាដើម។[៩] បន្តិចម្តងៗទំនាក់ទំនងយ៉ាងស្និតរមួតរវាងលោកពូទីននិងលោក Prigozhin នេះត្រូវបានស្តែងឡើងជាបន្តបន្ទាប់ តាមរយៈការងារផ្សេងៗជាច្រើនដោយរួមទាំងការផ្តល់ជូនលោក Prigozhin នូវកិច្ចសន្យារ៉ាប់រងក្នុងការផ្គត់ផ្គង់អាហារសម្រាប់សាលារដ្ឋនៅទីក្រុង Moscow ទាំងមូលមុខជំនួញផ្សេងទៀត និងឈានដល់វិស័យយោធា។

ជាងនេះទៅទៀតក្នុងឆ្នាំ២០១០ លោកពូទីនបានជួយបើករោងចក្ររបស់ Prigozhin ដែលត្រូវបានសាងសង់ឡើង ដោយប្រាក់កម្ចីដោយធនាគាររដ្ឋថែមទៀតផង។

---

[៩] VOA : Wagner Group's Prigozhin Has Long Ties to Putin,available in https://rb.gy/lp8xi, aceessed on June 27 ,2023 at 19:30 pm.

នៅទីក្រុងមូស្គូ ក្រុមហ៊ុនរបស់Prigzhin បានទទួលប្រាក់ចំណេញរាប់លានដុល្លារ ក្នុងកិច្ចសន្យាផ្គត់ផ្គង់អាហារនៅសាលារៀន។ Prigozhin ក៏បានទទួលសិទ្ធក្នុងការរៀបចំម្ហូបអាហារសម្រាប់ព្រឹត្តិការណ៍វិមានក្រឹមឡាំង អស់រយៈពេលជាច្រើនឆ្នាំដោយធ្វើឱ្យគាត់ទទួលបានរហស្សនាមថា **«ចុងភៅពូទីន»**[១០] និងបានផ្តល់ឱ្យក្រុមហ៊ុនលោកPrigozhin ក្នុងការផ្តល់សេវាកម្មម្ហូបអាហារ និងឧបករណ៍ប្រើប្រាស់ដល់យោធារុស្ស៊ី។

---

[១០] VOA : Wagner Group's Prigozhin Has Long Ties to Putin,available in https://rb.gy/lp8xi, aceessed on June 27 ,2023 at 19:30 pm.



រូបភាពពី
https://rb.gy/1opqy

ជារួម ទំនាក់ទំនងរវាងលោក ពូទីន និងលោក Prigozhin ហាក់មានភាពល្អូកល្អើននឹងគ្នាខ្លាំងណាស់ ជាដៃគូសហការរកស៊ីជាមួយគ្នាយ៉ាងជិតស្និទ្ធ តាំងពីមុនគាត់បង្កើតក្រុមWganerទៅទៀត ហើយគេជឿជាក់ថា ក្រុមទាហានស៊ីឈ្នួលនេះ បើគ្មានលោក ពូទីន នៅខាងក្រោយទេ គឺគាត់មិនអាចឈរជើងបានរឹងមាំយ៉ាងនេះទេ។ បើជិត

ស្ថិតិយ៉ាងនេះ ចុះហេតុអ្វីបានជានាំឱ្យលោកPrigozhin សម្រេចចិត្តដើរដល់ផ្លូវបំបែករវាងមិត្តភាពអ្នកទាំងពីរ?

### ផ្នែកទី៣. មូលហេតុដែលធ្វើឱ្យក្រុមWagnerបែរ កាណុងចូលMoscow

ចំណងមិត្តភាពរវាងMoscow និង ក្រុមទាហានស៊ីឈ្នួលWagner បានឈានដល់ស្ថានការណ៍ដែលមើលមុខគ្នាមិនចំយ៉ាងនេះ បន្តឡើងដោយហេតុផលចំនួន៥ ដែលលោក Prigozhin តែងបង្ហាញសារមិនពេញចិត្តរបៀបនេះតាមប្រព័ន្ធទំនាក់ទំនងសង្គមជាស្វែងរក

**ហេតុផលទី១.** លោក Pringozhin ខឹងសម្បាយ៉ាងខ្លាំងនឹងថ្នាក់ដឹកនាំយោធារុស្ស៊ី ដោយបានរិះគន់មិនសំចៃមាត់ និយាយប្រមាថទាំងមេបញ្ជាការកងទ័ពរុស្ស៊ី ទាំងរដ្ឋមន្ត្រីការពារជាតិរុស្ស៊ី ថា អសមត្ថភាព[១១] គ្មានយុទ្ធសាស្ត្រ

---

១១ ឈាង បុប្ផា : *មេក្រុមទាហានស៊ីឈ្នួលរុស្ស៊ី Wagner បែរទិសចេញពីអ៊ុយក្រែនទៅតទល់នឹងអំណាចយោធានៅរុស្ស៊ី*, RFI,ចេញផ្សាយថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២៣,available https://rb.gy/wlml1, aceessed on June 26 ,2023 at 11:30 am.

ប្រយុទ្ធនៅក្នុងសមរភូមិអ៊ុយក្រែន ហើយគោលដៅរបស់គាត់ទៅកាន់ក្រុងMoscow មិនមែនដើម្បីផ្តួលរលំលោកពូទីននោះឡើយ គឺចង់ទៅរកមេទ័ពរុស្ស៊ី។

**ហេតុផលទី២.** បើទោះបីជា ក្រុមWagnerនិង Moscow មានសត្រូវរួមគ្នាក៏ពិតមែនតែ នាពេលនេះ លោក Pringozhin បែរជាខឹងនឹងថ្នាក់ដឹកនាំកងទ័ពរុស្ស៊ី ដែលតែងតែកេងចំណេញយកក្រេឌីតពីលើក្រុមខ្លួនលើជ័យជម្នះនៅអ៊ុយក្រែន។ [១២]

**ហេតុផលទី៣.** លោក Prigozhin នៅបានចោទប្រកាន់រដ្ឋមន្ត្រីការពារជាតិរុស្ស៊ីថា មានចេតនាមិនផ្តល់អាវុធឱ្យទាហានស៊ីឈ្នួលរបស់ខ្លួន និងបានប្រព្រឹត្តអំពើពុករលួយយ៉ាងខ្លាំង។

**ហេតុផលទី៤.** មេក្រុមទាហានស៊ីឈ្នួល Wagner លោក Prigozhin ខឹងនឹងរដ្ឋមន្ត្រីការពារជាតិរុស្ស៊ីដែលបានទម្លាក់គ្រាប់បែក និងវាយឆ្មក់លើទាហានស៊ីឈ្នួល

---

១២ INDEPENDENT : What is the Wagner mercenary group led by Yevgeny Prigozhin?,available in https://rb.gy/t8kdi, aceessed on June 27 ,2023 at 19:30 pm.

Wagner ។ ការវាយប្រហារមកលើគ្នាឯងនេះ បណ្តាលឱ្យក្រុមទាហានស៊ីឈ្នួល Wagner បាត់បង់អាយុជីវិតអស់នាច្រើននាក់។

**ចំណែកហេតុផលទី៥.** គឺលោកPrigozin ចង់បានយុត្តិធម៌ពីសម្រាប់ក្រុមទាហានរបស់ខ្លួន។ ការលើកទ័ពទៅ Moscowនេះមិនមែនជារដ្ឋប្រហារយោធាទេ ប៉ុន្តែជាការស្វែងរកយុត្តិធម៌ប៉ុណ្ណោះ។ (១៣)



រូបភាពពី

https://rb.gy/t8kdi

១៣ ALJAZEERA Why Wagner mercenary force has moved against Russia's military ,available in https://rb.gy/t8kdi, acessed on June 27 ,2023 at 23:30 pm.

## ជ្រុងទី៤. ស្ថានភាពប្រយុទ្ធនៅសមរភូមិអ៊ុយក្រែន

សមរភូមិប្រយុទ្ធនៅលើទឹកដីអ៊ុយក្រែន បានអូសបន្លាយពេលជាងពីរឆ្នាំមកហើយ រាប់ចាប់តាំងពីការចូលឈ្លានពានទឹកដីអ៊ុយក្រែនដំបូងកាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២២មក ដែលកាលនោះមានសេចក្ដីរាយការណ៍ថា ដើមហេតុដំបូងគឺក្រុមទាហានស៊ីឈ្នួល Wagner បានបន្លំខ្លួនធ្វើជាទាហានអ៊ុនក្រែន [១៤] បើកការវាយប្រហារមកលើរុស្ស៊ី ហើយរុស្ស៊ីយកលេសនេះ ដើម្បីវាយសម្រុកចូលទឹកដីអ៊ុយក្រែនតែម្ដង។

មែនទែនទៅ មានភ្លើងច្បាស់ជាមានផ្សែង ហើយការលើកទ័ពចូលឈ្លានពានអ៊ុយក្រែន គឺមានហេតុផលធំនៅពីក្រោយ។ គេនៅចាំបានថា មុនឈានដល់ការចូលឈ្លានពាន

---

[១៤] BBC: What is Russia's Wagner Group of mercenaries in Ukraine?,available https://rb.gy/p7mww, aceessed on June 26 ,2023 at 15:30 pm.

អ៊ុយក្រែន ពោលគឺ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ [១៥] រុស្ស៊ីបានដាក់ សំណើដែលបញ្ជាក់ពីការទាមទាររបស់ខ្លួនទៅកាន់អង្គការណាតូ និងសហរដ្ឋអាម៉េរិក។ ដោយរុស្ស៊ីបានស្នើមិនឱ្យអ៊ុយក្រែន ចូលក្នុងអង្គការណាតូទេ តែណាតូ និងសហរដ្ឋអាម៉េរិកហាក់មិនសូវអើពើ ហើយអ្វីដែលរិមានក្រឹមឡាំងព្រួយបារម្ភនោះគឺថា អាម៉េរិកនឹងដាក់ពង្រាយកាំជ្រួច ឬខែលការពារមីស៊ីលនៅលើដីអ៊ុយក្រែន។ ម្យ៉ាងវិញទៀត ទីក្រុងMoscow បានស្នើឱ្យណាតូ បញ្ឈប់រាល់ការដាក់ពង្រាយមីស៊ីលផ្លោង រយៈចម្ងាយមធ្យមនៅក្នុងទ្វីបអឺរ៉ុប និងការកំណត់ការធ្វើសមយុទ្ធយោធានៅជិតព្រំដែនរុស្ស៊ី។ រុស្ស៊ីចាត់ទុកសកម្មភាពទាំងអស់នោះ គឺជាការគំរាមកំហែងដល់សន្តិសុខរុស្ស៊ី។ បើគិតត្រឹមខែមិថុនា ឆ្នាំ២០២៣នេះ ស្ថានភាពប្រយុទ្ធនៅបន្តមានភាពក្តៅគគុកនៅឡើយ ហើយក៏មិនទាន់មានសញ្ញាណចមចយនៅឡើយទេ ត្បិតបច្ចិមប្រទេសបង្កើនការផ្តល់ជំនួយយោធាបន្ថែមមក

---

១៥ ALJAZEERA: No, Russia will not invade Ukraine,available in https://rb.gy/fpt4f, aceessed on June 28 ,2023 at 19:30 pm.

អ៊ុយក្រែន ហើយរុស្ស៊ីក៏នៅបង្កើនការវាយប្រហារដដែល។ ពេលនេះ រុស្ស៊ីងណ្ដើមបានតំបន់អ៊ុយក្រែនមួយចំនួនមកក្រោមការកាន់កាប់របស់ខ្លួនដែលមាន ដូចជាតំបន់ LUHANSK, Bakhmut, Donetsk, Marinka, Mariupol,ZAPORIZHZHIA ជាដើម។ [១៦]

១៦ Wthe NEw York TIMES: Tracking the Russian Invasion of Ukraine ,available in https://rb.gy/39lx5, aceessed on June 28 ,2023 at 18:30 pm.




Sources: Imagery of the fighting; Institute for the Study of War with American Enterprise Institute's Critical Threats Project. The New York Times

រូបភាពពី
https://rb.gy/39lx5

ពិតណាស់ ពីដំបូងឡើយបញ្ហាអ៊ុយក្រែននិងរុស្ស៊ីគឺជារឿងទ្វេភាគី តែមកដល់ពេលនេះ សភាពការណ៍កាន់តែឡើងកម្តៅ ព្រោះវាបានចូលដល់ការប្រយុទ្ធដោយប្រយោល

រវាងរុស្ស៊ីនិងបក្សសម្ព័ន្ធណាតូ តាមរយៈការផ្តល់សព្វាវុធដល់អ៊ុយក្រែន។ ការណ៍នេះ នាំឱ្យប្រទេសលោកខាងលិចចំណេញ ព្រោះខ្លួនអាចមានលេស ស្នើសុំបង្កើនកញ្ចប់ថវិការបស់ខ្លួនទៅកាន់សភា ក្រោមរូបភាពផ្តល់ជំនួយដល់អ៊ុយក្រែន ជ្រុងម្ខាងទៀតចំណេញ ព្រោះពួកគេអាចសាកអាវុធដែលពួកគេទើបផលិតថ្មីៗ ថាតើវាមានប្រសិទ្ធភាពកម្រិតណា ឬត្រូវការបង្កើនបច្ចេកទេសផ្នែកណាទៀត។

ម្យ៉ាងវិញទៀត ការបញ្ជូនសព្វាវុធទាំងអស់នោះ ក៏ជាការផ្សព្វផ្សាយនូវសក្តានុពលអាវុធរបស់ពួកគេ ដើម្បីស្វែងរកទីផ្សារផងដែរ។ រីឯជ្រុងទី៣ ពួកគេអាចធ្វើឱ្យរុស្ស៊ីចំណាយលុយក្នុងសង្គ្រាមនេះ ឱ្យកាន់តែច្រើនមានចេតនារាំងខ្ទប់សេដ្ឋកិច្ចរុស្ស៊ី ក្រោយរុស្ស៊ីសំងំលក់ភោគផលធម្មជាតិនិងឧស្ម័នបានយ៉ាងច្រើននាពេលកន្លងមក។

ពិតណាស់សង្គ្រាមនេះ អ្នកដែលរងទុក្ខវេទនានោះគឺប្រជាជនស្លូតត្រង់ទាំង ប្រជាជនអ៊ុយក្រែននិងប្រជាជនរុស្ស៊ី ហើយវីរភាពមានតែលោកពូទីន និងលោកហ្សេលេនស្គី (ប្រធាធិបតីអ៊ុយក្រែន) ប៉ុណ្ណោះ។

## ផ្នែកទី៥. ស្ថានភាពសង្គម និងសេដ្ឋកិច្ចរុស្ស៊ី

ដើម្បីឆ្លើយតបទៅនឹង សកម្មភាពឈ្លានពានរបស់រុស្ស៊ីនៅអ៊ុយក្រែន បច្ចិមប្រទេសបានដាក់ទណ្ឌកម្មសេដ្ឋកិច្ចយ៉ាងនំណំមកលើរដ្ឋាភិបាលលោកពូទីន ដោយផ្តាច់រាល់ការរកស៊ីជាមួយក្រុមហ៊ុនរុស្ស៊ី និងបានដាក់ឱ្យរុស្ស៊ីនៅឯកោតែឯង។ ការណ៍នេះ ទំនងជាធ្វើឱ្យផលប៉ះពាល់ដល់សេដ្ឋកិច្ចរុស្ស៊ីចៀសមិនផុត។ម្យ៉ាងវិញទៀត វិបត្តិសង្គមក៏ជាបញ្ហាប្រឈមខ្លាំងណាស់ដែរ ដូចជាតម្លៃទំនិញឡើងថ្លៃ,អត្តិធរណានិងភាពអត់ការងារធ្វើរបស់យុវជន,បញ្ហាជនភៀសខ្លួនដែលគេចពីសង្គ្រាមនៅតាមព្រំដែនរុស្ស៊ីនិងអ៊ុយក្រែន សុទ្ធសឹងជាវិញ្ញាសាមួយដែលមិនមានភាពងាយស្រួលប៉ុន្មានទេដល់រដ្ឋាភិបាលក្រុងMoscow។

បើយោងតាម តាមការចុះផ្សាយ របស់គេហទំព័រ Economics Observatory បានបង្ហាញថា នៅដើមឆ្នាំ ២០២៣ GDP រុស្ស៊ីធ្លាក់ចុះ ចន្លោះចាប់ពី៧ទៅ១០%[១៧]

---

[១៧] Economics Observatory: What is the current state of the Russian economy under sanctions, available in https://rb.gy/84wby, aceessed on June 29 ,2023 at 15:30 pm.

វិឯការចំណាយប្រចាំឆ្នាំរបស់រុស្ស៊ី ក៏មានការប្រែប្រួលផង ដែរ។ ប្រភពដដែលនេះ ក៏បានបង្ហាញផងដែរថា កញ្ចប់ ថវិកាជាតិរុស្ស៊ីក្នុងឆ្នាំ២០២៣ បានចំណាយខ្លាំងលើ សន្តិសុខជាតិចំនួន៥០% បើធៀបទៅនឹងឆ្នាំ២០២២ បាន កាត់បន្ថយការចំណាយលើវិស័យសុខាភិបាលមានចំនួន ៩%, បន្ថយ២% លើវិស័យអប់រំ, បន្ថយ២៤% វិស័យហេដ្ឋា រចនាសម្ព័ន្ធនិងបន្ថយ១៩%[១៨] នៅក្នុងវិស័យឧស្សាហា កម្ម។ ទាំងអស់នេះ គឺស្ថិតនៅក្នុងបរិបទនៃឱនភាពថវិកា ដែលកើនឡើងយ៉ាងខ្លាំង។ ដូច្នេះ ស្ថានភាពសង្គមរុស្ស៊ី ទំនងស្ថិតនៅក្នុងដំណាក់កាលមួយដែលអួរអាប់ ហើយស្ថាន ភាពនេះវាក៏បាននះឥទ្ធិពលអវិជ្ជមានដល់ការដឹកនាំរបស់ លោកពូទីន និងប្រជាប្រិយភាពរបស់លោកផងដែរ។

ជារួម បើផ្អែកលើក្រុងទាំង៥ ដូចដែលបានរៀប រាប់ខាងលើ យើងអាចមើលឃើញនូវសេណារិយោចំនួន៤

[១៨] Economics Observatory: What is the current state of the Russian economy under sanctions, available in https://rb.gy/84wby, aceessed on June 29 ,2023 at 15:30 pm.

ជុំវិញរដ្ឋប្រហាររោទម្រង់កូនកាត់នៅរុស្ស៊ី កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣កន្លងទៅថ្មីៗនេះ។

**សេណារីយោទី១.** វាមាននយោបាយស្រោចគល់ឬនយោបាយកាំបិតចិតនឹងឯង ព្រោះលោក Prigozin គឺជាមិត្តល្អនឹងរដ្ឋាភិបាលមូស្គូ តែបែរជាទៅវាយបកខ្លួនឯងទៅវិញ។ ករណីបែបនេះ ក៏ធ្លាប់មានម្តងរួចមកហើយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក គឺអាល់កៃដាជាក្រុមមួយដែលអាម៉េរិកជួយទំនុបបម្រុង ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងវត្តមានកងទ័ពសហភាពសូវៀត ដែលបានវាយចូលទឹកដីអាហ្វហ្គានីស្ថានកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែក្រោយមកក្រុមអាល់កៃដា ក៏បានងាកទៅវាយបកលើអាម៉េរិកវិញ ដោយបើកយន្តហោះបុកអគារពាណិជ្ជកម្មពិភពលោកកាលពីថ្ងៃទី១១ កញ្ញា ឆ្នាំ២០០១។

**សេណារីយោទី២.** ជាយុទ្ធសាស្ត្រព្រួញមួយបាញ់បានសត្វប្រាំ។

**សត្វទី១.** គឺលើកពីទនេះ ចូលទៅមូស្គូទំនងជាដើម្បីបង្វែរស្ថានការណ៍មហាជនរុស្ស៊ី ក៏ដូចជាដើម្បីយកលេសនេះចេញវិធានការតឹងរឹង ក្នុងការគ្រប់គ្រងសភាព

ការណ៍ដែលកំពុងមានភាពតានតឹង ក្រោយទណ្ឌកម្មសេដ្ឋកិច្ច របស់បច្ចិមប្រទេស ព្រោះថាវានូចនៅលើគោកពេក បើពិនិត្យមើលលើចម្ងាយផ្លូវដែលក្រុម Wagner ចេញពីតំបន់ Rostov-on-Don ទៅទីក្រុង Moscowគឺមានចម្ងាយឆ្ងាយណាស់របាតនល់ទៅ៦៥១ម៉ាល៍ឬប្រហែលនឹង១ ០៣៨គ.ម ឯណោះ សំណួរសួរថា រយៈចម្ងាយផ្លូវយ៉ាងនេះ ហេតុអ្វីក៏ Wagner អាចវាយចូលបានស្រួលម្លេះ? ហេតុអ្វីកងទ័ពរុស្ស៊ីមិនមានការជូននំណឹងមកMoscow អំពីសភាពការណ៍នេះ ព្រោះ Rostov-on-Don ជាទីតាំងបញ្ជាការធំសម្រាប់ប្រតិបត្តិការនៅអ៊ុយក្រែន។ ឬមួយកងទ័ពរុស្ស៊ីនិងប្រជាជនរុស្ស៊ីមិនពេញចិត្តនឹងការដឹកនាំរបស់លោកពូទីន ទើបបើកផ្លូវឱ្យWagner ចូល? ព្រោះថា Wagner banលើកទ័ពចូលជិតនល់មូស្គូ ឆ្លងកាត់ក្រុងវ៉ារ៉ូញេស ហើយមិនមានការផ្ទុះអាវុធជាទ្រង់ទ្រាយធំទៀត តើនេះជាការព្រមព្រៀងគ្នា រៀបចំឆាកសំដែងរៀបចំឱ្យលើកទ័ពចូលឬមួយយ៉ាងណា?

**សន្មតទីពីរ.** គឺលោកពូទីនយកលេសនេះ ដើម្បីបង្វែរចំណាប់អារម្មណ៍សាធារណជនជាតិនិងអន្តរជាតិ ក្នុង

ការដកកងទ័ពដែលខ្លាំង និងទុកចិត្តរបស់ខ្លួនចេញពីអ៊ុយក្រែនទៅកាន់បេឡារូស ដើម្បីការពារក្បាលគ្រាប់នុយក្លេអ៊ែររបស់ខ្លួនដែលរុស្ស៊ីទើបតែកាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០២៣ ។

**សត្វទីបី.** ជាយុទ្ធសាស្ត្រមួយដែលរុស្ស៊ីអាចនឹងប្រើប្រាស់ទីតាំងនេះ ទំនងដើម្បីប្តូតាក់ទិកប្រយុទ្ធវាយសម្រុកចូលកាន់ទីក្រុងកៀវរបស់ប្រទេសអ៊ុយក្រែន ហើយទីតាំងពីព្រំដែនបេឡារូសមក គឺវាកៀកនឹងទីក្រុងកៀវម្យ៉ាងទៀតរុស្ស៊ី ប្រហែលមិនចង់អូសបន្លាយសង្គ្រាមឈ្លានពាននេះយូរទៀតនោះទេ។

**សត្វទីបួន.** រុស្ស៊ីដាក់ទ័ពស៊ីឈ្នួលនៅបេឡារូស ទំនងជាចន្ទល់មួយសំខាន់ដែរ ក្នុងការពាររដ្ឋាភិបាលលោកប្រធានាធិបតីបេឡារូស លោកអាលិចសេនកូស ព្រោះថា បច្ចិមប្រទេសមិនអាចជាន់នីបេឡារូសបានឡើយបើសិនជាលោកសេនកូសនៅបន្តកាន់តំណែង។ បេឡារូសជាទីកនីសំខាន់ ដែលបច្ចិមប្រទេសចូលទៅកៀកនឹងរុស្ស៊ីកាន់តែខ្លាំង។

**សត្វទីប្រាំ.** រុស្ស៊ីប្រើទាហានស៊ីឈ្នួលនេះ ក៏ទំនង ដើម្បីបង្ការនិងទប់ទល់ប្រទេសប៉ូឡូញ ឬក្រុមបច្ចិមប្រទេសផងដែរ។ ជាការពិត ប៉ូឡូញជាបក្សសម្ព័ន្ធណាតូ ហើយបើរុស្ស៊ីប៉ះប៉ូឡូញក៏មិនមែនជារឿងស្រួលពេកទេ តែបើជាទាហានស៊ីឈ្នួលជាអ្នកប៉ះពាល់ ឬគំរាមកំហែងដល់ប៉ូឡូញទំនងជាអាចរឿងផ្សេងពីករទំពរុស្ស៊ីផ្ទាល់។

**សេណារីយោទី៣.** យុទ្ធសាស្ត្រយកពិសបន្សាបពិស ពិតណាស់រុស្ស៊ី ឈ្លានពានអ៊ុយក្រែនដោយជួលក្រុមទាហានស៊ីឈ្នួលនេះ។ ដូច្នេះ គេប្រើវិធីវាយបកយកក្រុមនេះ យកប្រយុទ្ធតទល់នឹងរុស្ស៊ីវិញ ព្រោះពាក្យថាស៊ីឈ្នួលមិនមែនជាកម្មសិទ្ធិផ្ដាច់មុខរបស់ក្រុមណាមួយឡើយ ឱ្យតែខាងណាផ្ដល់ថ្លៃខ្ពស់ជាងហើយត្រូវរ៉ូវគ្នា គេនឹងធ្វើការឱ្យអ្នកនោះ។ ហេតុនេះ អាចជាក្រុមណាមួយប្រើវិធីនេះ ដើម្បីឱ្យរុស្ស៊ីធ្វើសង្គ្រាមនឹងគ្នាឯង ពេលនោះសមត្ថភាពរុស្ស៊ីនឹងកាន់តែថមថយ ព្រោះចូលអន្ទាក់កាប់សម្លាប់គ្នាឯង។

**សេណារីយោទី៤.** រុស្ស៊ីនិងអាម៉េរិក ប្រហែលជាអាចមានការពិភាក្សាគ្នាដោយសម្ងាត់ណាមួយមុន ឬឯកភាពគ្នាមិនឱ្យអ៊ុយក្រែនចូលជាបក្សសម្ព័ន្ធណាតូ។ អញ្ចឹងដើម្បី

មុកមុខឱ្យគ្នា រុស្ស៊ីបង្កើតព្រឹត្តិការណ៍នេះដើម្បីយកលេសនកទំព និងបន្ថយការវាយប្រហារនៅអ៊ុយក្រែន ព្រោះខ្លួនបានផ្តល់មេរៀនឱ្យអ៊ុយក្រែន និងបានកាន់កាប់ទឹកដីអ៊ុយក្រែន ធ្វើជាតំបន់ទ្រនាប់រួចហើយ។ ហេតុការណ៍នេះស្រដៀងគ្នានេះ ក៏ធ្លាប់កើតមានហើយ គឺមុនសង្គ្រាមលោកលើកទី២ បញ្ចប់មហាអំណាចពេលនោះមានអង់គ្លេសបារាំង អាមេរិក និងសូវៀត ជជែកគ្នាមុនដើម្បីបែងចែកទឹកដីអាល្លឺម៉ង់ដើម្បីគ្រប់គ្រង។

**សេណារីយោទី៥.** មនុស្សយល់ចិត្តធ្វើបាបចិត្ត ពិតណាស់ Prigozine ជាមនុស្សជំនិតនឹងលោកពូទីន ហើយធ្វើបែបនេះបានដោយសារកាលៈទេសៈបង្ខំ ហើយនៅក្នុងពិភពលោកក៏មានដែរ ដែលមនុស្សជំនិតបំផុតងាកមកវាយបកមាន ដូចជាលោកប្រធានាធិបតីកូរ៉េខាងត្បូង Park Chung Hee ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៩ ដោយមនុស្សជំនិតគាត់មានឋានៈប្រធានសន្តិសុខគាត់ផ្ទាល់តែម្តង។

សរុបសេចក្តីមក សេណារីយោទាំងនេះ អាចនឹងលេចចេញមួយណាច្បាស់ជាងគេ គឺរង់ចាំពេលវេលាមក

នល់ ព្រោះថាមានតែពេលវេលាទេដែលអាចបកស្រាយធាតុពិតបាន។

## គន្ថនិទ្ទេស


១. ALJAZEERA: Wagner boss calls off march on Moscow, agrees to exile in Belarus ,available in https://rb.gy/ilglz, aceessed on June 26 ,2023 at 11:30 am.

២. Sky news: How does Wagner Group's strength measure up to the Russian state military? ,available https://shorturl.at/pyR14, aceessed on June 26 ,2023 at 15:30 pm.

៣. BBC: What is Russia's Wagner Group of mercenaries in Ukraine?,available https://rb.gy/p7mww, aceessed on June 26 ,2023 at 15:30 pm.

៤. ឈាង បុប្ផា : មេក្រុមទាហានស៊ីឈ្នួលរុស្ស៊ី Wagnerបែរទិសចេញពីអ៊ុយក្រែនទៅតទល់នឹងអំណាចយោធានៅរុស្ស៊ី, RFI,ចេញផ្សាយថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២៣,available

https://rb.gy/wlml1, aceessed on June 26 ,2023 at 11:30 am.

៥. mail onlline: How many soldiers do Wagner Group have against Russia? What weapons are at their disposal?,available in https://rb.gy/1opqy, aceessed on June 27 ,2023 at 16:30 pm.

៦. Time : What to Know About Notorious Mercenary Organization 'The Wagner Group' and Its Founder,available in https://rb.gy/ptgkf, aceessed on June 27 ,2023 at 19:30 pm.

៧. VOA : Wagner Group's Prigozhin Has Long Ties to Putin,available in https://rb.gy/lp8xi, aceessed on June 27 ,2023 at 19:30 pm.

៨. INDEPENDENT : What is the Wagner mercenary group led by Yevgeny Prigozhin?,available in https://rb.gy/t8kdi, aceessed on June 27 ,2023 at 19:30 pm.

៩. ALJAZEERA Why Wagner mercenary force has moved against Russia's military ,available in https://rb.gy/t8kdi, aceessed on June 27 ,2023 at 23:30 pm.

១០. ALJAZEERA: No, Russia will not invade Ukraine,available in https://rb.gy/fpt4f, aceessed on June 28 ,2023 at 19:30 pm.

១១. Wthe NEw York TIMES: Tracking the Russian Invasion of Ukraine ,available in https://rb.gy/39lx5, aceessed on June 28 ,2023 at 18:30 pm.

១២. Economics Observatory: What is the current state of the Russian economy under sanctions, available in https://rb.gy/84wby, aceessed on June 29 ,2023 at 15:30 pm.

១៣. https://cisac.fsi.stanford.edu/mappingmilitants/profiles/al-qaeda

១៤. https://www.britannica.com/biography/Park-Chung-Hee